ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# លិខិតជូនពរ

## សូមគោរពជូន

## លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង រដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច

## ក្នុងឱកាសទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២២

**លោកជំទាវកិត្តិសង្គហបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១១១ នៃទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២២ នេះ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមអបអរសាទរដោយសេចក្តីសោមនស្សរីករាយក្រៃលែង និងសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យនិងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរជូន **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃ និងជ័យជម្នះគ្រប់ប្រការ ដើម្បីបន្តដឹកនាំការងារក្រសួងឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។

ក្នុងឱកាសនៃទិវានារីអន្តរជាតិដ៏ថ្លៃថ្លានិងមានអត្ថន័យនេះ យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ **លោកជំទាវកិត្តិសង្គហបណ្ឌិត** ដោយស្មោះអស់ពីដួងចិត្ត ចំពោះស្នាដៃការងារបម្រើជាតិមាតុភូមិ ក៏ដូចជាវីរភាពគំរូដ៏ឧត្តុង្គឧត្តមក្នុងតួនាទីភារកិច្ចដឹកនាំក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រួមចំណែកជាមួយប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្នុងការងារលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា ដែលជាឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា។ ជាពិសេស **លោកជំទាវកិត្តិសង្គហបណ្ឌិត** ជាកុលធីតាខ្មែរដ៏ឆ្នើមមួយរូបដែលបានរួមចំណែកក្នុងពលិកម្មគ្រប់បែបយ៉ាងដើម្បីសន្តិភាពនិងការរីកចម្រើននៃសង្គមជាតិកម្ពុជានាពេលបច្ចុប្បន្ន ហើយក៏ជាគំរូដ៏ឧត្តមដល់ស្ត្រីខ្មែរទូទៅ តាមរយៈការចូលរួមគ្រប់សកម្មភាពលើកកម្ពស់តម្លៃសីលធម៌សង្គមខ្មែរ និងការរក្សាការពារនិងលើកស្ទួយតម្លៃនិងសិទ្ធិស្ត្រីខ្មែរទូទៅ។

យើងខ្ញុំទាំងអស់គ្នាសូមគោរពជូនពរ **លោកជំទាវកិត្តិសង្គហបណ្ឌិត** និងក្រុមគ្រួសារ សូមមានសុខភាពល្អបរិបូរណ៍ និងសមប្រកបនូវព្រះពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃ សុក្រ ២ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី 04 ខែ មីនា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

ព្រុំ-សុខា